ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៥
ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩
សាលក្រមព្រហ្មទណ្ឌលេខ ៦១ "ធ"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ស្ពឺ**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកំពង់ស្ពឺ
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ វេលាព្រឹក
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ វេលាព្រឹក

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈ ចៅក្រម

**តំណាងអយ្យការ**

លោក [redacted] ឋានៈ ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជី

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ហុក សារីជ័យសួរវង្ស។

និងលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ហុក យីវឆាយ។

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] យីវឆាយ ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រះត្រពាំង (ប្រទេសវៀតណាម) ទីលំនៅបច្ចុប្បន្នភូមិក្របីត្រាំ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សល់ (រស់) ម្តាយឈ្មោះ [redacted] តាយីវ (រស់)ប្រពន្ធឈ្មោះ [redacted] ឡូវីន (រស់) មានកូន០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន, កំរិតវប្បធម៌ថ្នាក់ទី៣។ (ក្រៅឃុំ)

ជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៤។

**ដើមបណ្តឹងរដ្ឋប្បវេណី**

-ឈ្មោះ [redacted] សារីជ័យសួរវង្ស ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ និស្សិត អាសយដ្ឋានសព្វថ្ងៃផ្ទះលេខ:... ផ្លូវជាតិលេខ៣ ភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

**អង្គហេតុកើតឡើងមានដូចតទៅ**

កាលពីអំឡុងឆ្នាំ២០១៤ ស្ថិតនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានករណីរំលោភលើទំនុកចិត្តមួយបានកើតមានឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ [redacted] យីវឆាយ ភេទប្រុស អាយុ៣៤ឆ្នាំ បានទៅយកប្រាក់ពីព្រះចៅអធិការវត្តជង្រុក ព្រះនាម [redacted] មុន្នី ដើម្បីយកទៅទិញដី ដែលប្រាក់នោះគឺជាប្រាក់របស់ឈ្មោះ [redacted] សារី បានផ្ញើទុកឱ្យទិញដីដាក់ឈ្មោះកូនប្រុសរបស់គាត់ឈ្មោះ [redacted] សារីជ័យសួរវង្ស តែក្រោយពេលដែលឈ្មោះ [redacted] យីវឆាយ ទទួលបានប្រាក់ពីព្រះសង្ឃ [redacted] មុន្នី រួចហើយ ឈ្មោះ [redacted] យីវឆាយ

មិនបានយកទៅទិញដីតាមការសន្យាទេ បែរជាយកទៅលេងភាគហ៊ុនចាញ់អស់ទៅវិញ។ រហូតមកដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ ទើបឈ្មោះ [redacted] សារីជ័យសូរវង្ស បានដឹងហើយក៏ដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺតែម្តង។

-បានឃើញ ដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនលេខៈ ១៥៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៧៥៥៣ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៦៩២ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៦៦៥ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ការផ្តល់ និងជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការដែលធ្វើឡើងដោយអនុឡោមតាមបញ្ញត្តិមាត្រា២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## នាពេលសវនាការ

១-ក្រឡាបញ្ជីអានអំណានចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ បានឆ្លើយសារភាពថាៈ ខ្លួនមិនបានយកលុយពីលោកតាព្រះនាម [redacted] មុន្នី ដែលជា ចៅ អធិការវត្តជង្រុកដូចការអះអាងរបស់គាត់ថាបានយកមកទិញដី ដើម្បីឱ្យទៅឈ្មោះ [redacted] សារីជ័យសូរវង្ស នោះទេ។ ចំពោះខ្សែអាត់សម្លេងដែលដើមបណ្តឹងបានដាក់ជូនតុលាការនោះគឺមិនទទួលស្គាល់ទេ ព្រោះការចរចារទាំងអស់នោះគឺមានរយៈពេលដល់ជាងមួយម៉ោងឯណោះ មិនមែនត្រឹមតែ១៦នាទីទេ ហើយខ្លួនទទួលស្គាល់ថាសម្លេងក្នុងខ្សែអាត់នោះ គឺជាសម្លេងរបស់ខ្លួនប្រាកដមែន។ មូលហេតុដែលនៅក្នុងខ្សែអាត់សម្លេងដែលខ្លួនថាបានយកលុយលោកទៅលេងភាគហ៊ុនទឹកចាញ់អស់នោះ គឺជាពាក្យជីជងគ្នាតែប៉ុណ្ណោះ ការពិតគឺមិនបានយកលុយពីលោកទេ។ ចំពោះដីចំនួនពីរកន្លែងដែលខ្លួនទិញនោះ គឺបានទិញពិតប្រាកដមែន ប៉ុន្តែមិនមែនខ្លួនជាអ្នកទិញទេ គឺឪពុកក្មេកជាអ្នកទិញហើយបានចែកមកឱ្យកូនជាចំណងដៃ ដោយដីមួយកន្លែងនោះមានតម្លៃ ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ ប្រាំរយ) ដុល្លារអាមេរិក ហើយបានចែកមកឱ្យកូនចំនួនពីរនាក់ដែលដាក់ឈ្មោះខ្លួន និងប្រពន្ធហើយមានចំណែកប្អូនថ្លៃពៅនៅទីនោះដែរ ចំណែកដីមួយកន្លែងទៀតមានតម្លៃ ២៤,០០០ (ពីរម៉ឺនបួនពាន់) ដុល្លារអាមេរិក ហើយបានដាក់ឈ្មោះខ្លួនជាម្ចាស់ដី តែពេលធ្វើកិច្ចសន្យាបានដាក់តម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ហើយមូលហេតុដែលដាក់តម្លៃលើសការពិតគឺដោយសារឪពុកក្មេកខ្លួនជាអ្នករកស៊ីដីហេតុនេះត្រូវដាក់តម្លៃឱ្យលើស ដើម្បីយកផលចំណេញ។ ដីដែលឪពុកក្មេកខ្លួនទិញនោះ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ ដោយដីតម្លៃ ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក មានទីតាំងនៅភូមិកាយីវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយលុយនេះគឺជាលុយរបស់ឪពុកក្មេកខ្លួន ដោយឪពុកក្មេកខ្លួនជាអ្នករកស៊ីគក់ដេរដី និងលក់ខោអាវ ចំពោះដីតម្លៃ ២៤,០០០ដុល្លារ (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) ទិញនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដីនេះគឺ ទិញក្រោយទេ ប្រហែលជាឆ្នាំ២០១៦ គឺជាលុយចំនួន ៦,០០០ដុល្លារ (ប្រាំមួយពាន់ដុល្លារអាមេរិក) ក្រៅពីនោះជា លុយពីបងថ្លៃខ្លួន ដោយបងថ្លៃគឺជាដុកទ័រ ខ្លួនបានចូលគ្នាដោយចូលគ្នាជាមួយប្អូនថ្លៃហើយដីនោះបានដាក់ ឈ្មោះខ្លួនជាម្ចាស់។ ពេលដែលប្រគល់លុយថ្លៃដីដែលមានតម្លៃ ៥១,៥០០ដុល្លារ (ប្រាំម៉ឺនមួយពាន់ប្រាំរយដុល្លារអាមេរិក) មានទីតាំងភូមិកាយីវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ គឺមិនបានយកលុយទៅប្រគល់ឱ្យទៅគេផ្ទាល់ទេ គឺផ្តិតតែមេដៃលើឯកសារប្រគល់លុយតែប៉ុណ្ណោះ។ ចំពោះដីតម្លៃ ២៤,០០០ ដុល្លារ (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) ទិញនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ គឺខ្លួនជាអ្នកយកទៅប្រគល់ឱ្យម្ចាស់ដីផ្ទាល់ តែដីចំនួនពីកន្លែងនោះគឺខ្លួនបានលក់អស់មួយកន្លែងទៅហើយ គឺលក់នៅភូមិបាក់ក



Scanned with CamScanner

បញ្ជាក់តែទៅលើភាពត្រឹមត្រូវស្នាមមេដៃរបស់គូភាគីលើឯកសារទាំងនោះប៉ុណ្ណោះ លោកពុំបានបញ្ជាក់ និងទទួលស្គាល់ពីភាពត្រឹមត្រូវនៃទំហំដីដែលមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី កិច្ចសន្យាលក់ផ្តាច់ និងលិខិតធានាអះអាងដែលពាក់ព័ន្ធនឹងដីខាងលើឡើយ។ លោកក៏បានបដិសេធ និងមិនទទួលស្គាល់ចំពោះសកម្មភាពរបស់ឈ្មោះ [redacted] នាក់ និងឈ្មោះ [redacted] សុផា ដែលបានបោះបង្គោលព្រំដីខុសពីទំហំពិតប្រាកដរបស់ម្ចាស់ដើម និងព្រំប្រទល់ដីដែលខ្លួនទទួលស្គាល់នៅពេលមានការវាស់វែងដោយក្រុមការងារថ្នាក់ជាតិផងដែរ។

៥.ដើមចោទបានសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយធ្វើការរុះរើសំណង់ផ្សេងៗដែលមាននៅលើដីខ្លួន ឃើញថាដើមចោទពុំមានភស្តុតាងបញ្ជាក់ថាចុងចម្លើយបានរំលោភចូលកាន់កាប់ទេ តុលាការគប្បីប្រានចោលការទាមទារ តាមមាត្រា ១៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៦.ដើមចោទសុំឱ្យតុលាការប្រកាសអនុវត្តសាលក្រមបណ្តោះអាសន្ន ឃើញថា ពុំមានមូលហេតុត្រឹមត្រូវតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ។

៧.តាមការពិនិត្យពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ភាគីដើមចោទ, តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យគូភាគី និងការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ដីទំហំទទឹងជាប់មាត់សមុទ្រ ១៤០ ម៉ែត្រ និងបណ្តោយ ៣០០ ម៉ែត្រ ស្ថិតនៅភូមិព្រែកស្វាយ សង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានក្បាលដីលេខ ២៧១ ពុំមានកិច្ចសន្យាទិញលក់រវាងភាគីដើមចោទ និងភាគីចុងចម្លើយឡើយ ហើយក៏ពុំមានទិន្នន័យព័ត៌មានក្បាលដីដែលបញ្ជាក់ថាជាកម្មសិទ្ធិរបស់ភាគីណាមួយឡើយ។

៨.តាមប្រកាសអន្តរក្រសួងស្តីពីការកំណត់ការកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លីលេខ ០២ ប្រកន/០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឃើញថា ដីទំហំ ទទឹងជាប់មាត់សមុទ្រ ១៤០ ម៉ែត្រ និងបណ្តោយ ៣០០ ម៉ែត្រ ស្ថិតនៅ ភូមិព្រែកស្វាយ សង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានក្បាលដីលេខ ២៧១ ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី (ប្រការ១, ប្រការ២ និងប្រការ៤ នៃប្រកាសអន្តរក្រសួងខាងលើ)។

ប្រការ១ បានចែងថា វិវាទដីធ្លីទាំងឡាយត្រូវបែងចែកទៅតាមសមត្ថកិច្ចនីមួយៗដូចតទៅះ វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសម្គាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវឋិតក្នុងសមត្ថកិច្ចរបស់តុលាការ។ វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺជាដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវឋិតក្នុងសមត្ថកិច្ចគណៈកម្មការសុរិយោដី។

ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានតម្លៃ ២៤,០០០ដុល្លារ (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) ដោយលក់ប្រហែលជា២ឆ្នាំទៅហើយ។ ដើមបណ្ដឹងឈ្មោះ [redacted]សារីជ័យសួរវង្ស ត្រូវជា ប្អូនជាដូនមួយបង្កើតរបស់ខ្លួន ហើយលោកតា [redacted] មុន្នី ក៏ត្រូវជាឪពុកមារបស់ខ្លួនដែរ ចំពោះការចោទប្រកាន់ថាយកលុយពីប្អូនរបស់លោកឈ្មោះ [redacted] សារី ត្រូវជាពូរបស់ខ្លួន ដែលបានផ្ញើមកឱ្យលោកតា [redacted] មុន្នី ហើយថាបានប្រគល់លុយនោះឱ្យមកខ្លួនយកមកទិញដីឱ្យទៅប្អូនឈ្មោះ [redacted]សារីជ័យសួរវង្ស គឺមិនពិតនោះទេ ព្រោះខ្លួនមិនដែលបានទទួលលុយពីលោកឡើយ។ខ្លួនទទួលស្គាល់ថាកន្លងមកធ្លាប់នៅជាមួយលោកតា [redacted] មុន្នី ដោយបានបួសជាសង្ឃនៅឆ្នាំ២០០០ ក្រោយមកសឹកនៅក្នុងឆ្នាំ២០១២ ដោយបានស្រលាញ់គេហើយ លោកតាក៏បានជួយរៀបការឱ្យដែរ បន្ទាប់ពីរៀបការរួចខ្លួនក៏មិនដែលបានមកទំនាក់ទំនងអ្វីជាមួយលោកដែរ ហើយពេលរៀបការនោះលោកតា [redacted] មុន្នី ក៏បានឱ្យលុយមកខ្លួនចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ដោយចាំដប់ឆ្នាំក្រោយសងឱ្យទៅគាត់វិញក៏បានដែរ។ ខ្លួនស្គាល់ឈ្មោះ [redacted] ស្មាន់ ដោយគាត់ត្រូវជាជីតា ហើយគាត់ត្រូវជាឪពុកមារបស់លោកតា [redacted] មុន្នី ខ្លួនក៏មិនដែលមានគំនុំឬក៏មិនមានទំនាស់អ្វីជាមួយនឹងគាត់ដែរ ចំពោះការលើកឡើងថាបាន ឃើញខ្លួនទៅយកលុយពីលោកនោះគឺសុំបដិសេធចោលព្រោះមិន មែនជាចំលើយដែលជាការពិតនោះទេ។ ចំណែកចម្លើយរបស់អាជ្ញាធរស្រុកឈ្មោះ [redacted] សំណាង គឺជាចម្លើយមិនពិតទេ ព្រោះខ្លួនមិនបាននិយាយអ្វីដែលឈ្មោះ [redacted] សំណាង លើកឡើងឡើយ តែទទួលស្គាល់ថាពិតជាបានជួបឈ្មោះ [redacted]សំណាង មែន។ ខ្លួនស្គាល់សាក្សីឈ្មោះ [redacted] សុខ ឈ្មោះ [redacted] ឡេង ឈ្មោះ [redacted] សុខា ឈ្មោះ[redacted]សារុន ឈ្មោះ[redacted]ឡេង ព្រោះពួកគាត់ជាចាស់ទុំនិងជាអាចារ្យវត្តជង្រុក ហើយខ្លួនក៏មិនមានទំនាស់អ្វីជាមួយនឹងពួកគាត់ដែរ។ ចំពោះចម្លើយដែលគាត់បានឆ្លើយជូនតុលាការនោះក៏ខ្លួនមិនដឹងថាការពិតឬមិនការពិតនោះទេ។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីជ័យសួរវង្ស ឆ្លើយបំភ្លឺថាៈ ឪពុកខ្លួន ([redacted] សារី) បានលក់ដីស្រែចំការ លក់ត្រាក់ទ័រ និងបានលុយពីធនាគារខ្លះ និងបានផ្ញើលុយទៅព្រះគ្រូចៅអធិការដើម្បីទុកឲ្យលោកហុក យីវឆាយ ជួយរកទិញដី ពេលទិញបានហើយគឺដាក់ឈ្មោះខ្លួន។ លុយដែលឪពុកខ្លួនផ្ញើនិងព្រះចៅអធិការនោះគឺមានចំនួន ៩៥០០០ដុល្លារ (ប្រាំបួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។ នៅថ្ងៃដែលហុក យីឆាយ ទៅថ្វាយបង្គំព្រះអង្គដើម្បីដកលុយទិញដីនោះ ខ្លួនក៏បានទទួលព័ត៌មានដែល ដោយគាត់ទូលព្រះអង្គថា រកដីបានហើយនៅភូមិកាយីវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានទំហំ ៤៩ម៉ែត្រ គុណនិង៤៧ម៉ែត្រ ក្នុងតម្លៃ៥១៥០០ដុល្លារ។ ពេលដែលឈ្មោះ [redacted] យីវឆាយ មកយកលុយនោះ គឺមិនបានធ្វើលិខិតស្នាមអ្វីទេ ដោយសារតែគាត់ត្រូវពូបង្កើតរបស់ព្រះអង្គ និងត្រូវជាក្មួយរបស់ប៉ាខ្លួនដែរ។ ពេលដែលគាត់យកលុយទៅនោះឪពុកខ្លួន និងខ្លួនបានសួរនាំរកលិខិតស្នាមផងដែរ ប៉ុន្តែគាត់បាននិយាយថាទិញដីនោះត្រូវការសួរិយោដីវាស់វែង និងមានមូលហេតុជាច្រើន ពេលគាត់ចាត់ចែងឯកសាររួចគាត់និងប្រាប់ខ្លួនឲ្យផ្តិតមេដៃ។ ចាប់តាំងពីគាត់រកដីបានក្នុងឆ្នាំ២០១៤ ខ្លួនបានសួរនាំរកលិខិតដែរ តែគាត់បានលើកហេតុផលជាច្រើន និងយល់ថាកូនក្មួយទើបមិនសួរនាំច្រើន ណាមួយគឺមានទំនុកចិត្តលើគាត់ផង។ ក្រោយមកទើបដឹងថាគាត់បានយកដីដែលរកទិញបានមកដាក់ឈ្មោះខ្លួនគាត់ជាម្ចាស់កម្មសិទ្ធិទៅវិញ ដោយសារតែបែកធ្លាយនៅថ្ងៃធ្វើបុណ្យក្នុងឆ្នាំ២០១៩។ មូលហេតុដែលខ្លួនដឹងនោះដោយសារតែពេលមកយកលុយ និងមានសាក្សីឈ្មោះ [redacted] ស្មាន់ ដែលមកយកលុយពីព្រះគ្រូចៅអធិការ។ នៅឆ្នាំ២០១៦ គាត់បានទូលព្រះអង្គថារកដីបានមួយកន្លែងទៀតនៅផ្លូវលេខ៤១ និងបានសុំលុយពីព្រះអង្គ ៣០០០០ដុល្លារ ដោយគាត់មកជាមួយនិងឈ្មោះ [redacted] ស្មាន់ ចំពោះទំហំនោះខ្លួនមិនចាំនោះទេ ដើម្បីយកទៅទិញដី មុននិងប្រគល់លុយព្រះអង្គបានទំនាក់ទំនងជាមួយឪពុកខ្លួនតាមរយៈទូរស័ព្ទដែរ ហើយព្រះអង្គបានសង្ឃដីកាថាលុយនេះជាលុយរបស់ឪពុកខ្លួន ពេលទិញដីបានហើយត្រូវតែ ដាក់ឈ្មោះឲ្យក្មួយគាត់។ រយៈពេលនៃការទិញដីលើកមុន និងលើកក្រោយគឺមានរយៈពេលពីរឆ្នាំ មូលហេតុដែលព្រះអង្គប្រគល់លុយឲ្យគាត់ទិញដីថែមទៀតនោះ ដោយមិនទាន់មានឯកសារលើកមុនដោយព្រះអង្គយល់ថាជាពូក្មួយ។



Scanned with CamScanner

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ៩ព្រឹក នៅផ្ទះ [redacted] យីវឆាយ ពេលនោះខ្លួនរួមជាមួយឈ្មោះ [redacted] ស្មាក់ ហៅ [redacted] ស្មាក់, [redacted]វ៉ាល់, [redacted]ផន និងលោក [redacted] សំណាង បានទៅដល់ផ្ទះហ៊ុក យីវឆាយ តាមការណាត់ផ្ទាល់មាត់របស់ឈ្មោះ [redacted] យីវ ឆាយ ឲ្យខ្លួនហៅអាជ្ញាធរភូមិ-ឃុំ-ស្រុក ទៅផ្ទះរបស់គាត់ដើម្បីផ្ទេរសិទ្ធិដីទាំងពីរកន្លែងមកដាក់ឈ្មោះខ្លួនវិញ។ ពេលមកដល់ផ្ទះ [redacted] យីវឆាយ ខ្លួនបានជួបឪពុកក្មេករបស់គាត់ ហើយឪពុករបស់គាត់ឈ្មោះ [redacted]វ៉េត បាន និយាយថា អាឆាយ យកលុយពី មាណា មាណី មកទិញដីពុះមួយចំហៀងនោះគាត់មិនដឹងទេ។ ទើបប្តាយបែក ពេលនោះដោយឈ្មោះ [redacted] យីវឆាយ ប្រាប់ឪពុកក្មេកគាត់ថា លុយទទួលបានមកមែនតែត្រូវ [redacted] យីវឆាយ យកទៅដាក់ភាគហ៊ុនរដ្ឋករទឹកខាតអស់ទៅ។ ពេលកំពុងនិយាយស្រាប់តែឈ្មោះ [redacted]យីវឆាយ ក៏ចូលមកដល់ហើយខាងអាជ្ញាធរបានសួរទៅឈ្មោះ [redacted] យីវឆាយ ហើយគាត់បានឆ្លើយបញ្ជាក់ថា: មានដីគេលក់ ១០០ម៉ែត្រ ប៉ា [redacted]វ៉េត), មាន ៥០ម៉ែត្រ និងសល់ ៥០ម៉ែត្រ ខ្លួនប្រាប់ទៅលោកតា សាន មុន្នី ជាព្រះចៅអធិការវត្តជង្រុក ហើយលោកថា មានលុយអញ្ចឹងនៅ ៥០ម៉ែត្រ នេះមកយកមោ ខ្លួនក៏ទៅយកលុយពីលោកចំនួន ៥១៥០០ ដុល្លារ (ប្រាំម៉ឺនមួយពាន់ប្រាំរយដុល្លារ)។ ឈ្មោះ [redacted] យីវឆាយ បានឆ្លើយបញ្ជាក់ទៀតថាខ្លួនបានទៅយកលុយពីលោកចំនួន ៥១៥០០ដុល្លារ ដើម្បីយកទៅទិញ ដីចំនួន៥០ម៉ែត្រឲ្យគ្រប់ ពេលដែលខ្លួនយកលុយចំនួន ៥១៥០០ដុល្លារ ហើយប្រាប់ប៉ាក្មេកថាបានលុយពីវត្តតែប៉ាក្មេកឥតប៉ះពាល់ទេឲ្យយកទៅសងលោកវិញ តែឈ្មោះ [redacted] យីវឆាយ មិនបានយកទៅសងលោកវិញនោះទេដោយសារខ្លួនលេងភាគហ៊ុនខាតខ្លួនក៏យកលុយនោះទៅបូកភាគហ៊ុនទៀត (លេងភាគហ៊ុនរដ្ឋករទឹកស្វ័យតលុយនេះខ្លួនយកទៅដោះសងគេទៅ រឿងនេះខ្លួនបិទរហូត ៥ ទៅ ៦ឆ្នាំហើយ ខ្លួនក៏មិនបានផ្តល់ ព័ត៌មាននេះទៅលោកវិញនោះទេ ដោយខ្លាចលោកខ្វាល់ណាមួយលោកឆេវឆាវមិនប្រាប់រឿងដល់លោកដោយ គិតថាថ្ងៃក្រោយខ្លួនរកស៊ីបានលៃអីខ្លួននិងបង្វិលលុយសងលោកវិញ ថាខ្លួនបោកប្រាស់លោកក៏ថាបានព្រោះវាកំហុសរបស់ខ្លួន។ ក្នុងពេលនិយាយឆ្លើយឆ្លងនោះខ្លួន បានថតសម្លេងទាំងអស់តាមរយៈទូរស័ព្ទដៃរបស់ខ្លួន។ នៅពេលនេះសំណូមពរសូមឱ្យតុលាការធ្វើការឃុំខ្លួននិងផ្តន្ទាទោសឈ្មោះ [redacted] យីវឆាយ តាមច្បាប់និង សូមទាមទារសំណងជម្ងឺចិត្តចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

៣-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សួរដើមបណ្តឹង : លុយដែលនៅសល់នៅនិងព្រះអង្គនៅឡើយ។ នៅពេលដែលទទួលលុយពីព្រះអង្គ [redacted] មុន្នី ខ្លួនមិននៅទីនោះទេ ហើយក៏គ្មានលិខិតប្រគល់ទទួលប្រាក់ដែរ បានជាមិនធ្វើលិខិតនោះដោយសារយល់ថាបងប្អូន។

៤-សាក្សីឈ្មោះ [redacted]ឡេង បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ខ្លួនបានលឺឈ្មោះ [redacted] សារី បានផ្ញើលុយទុកឲ្យព្រះសង្ឃ ដើម្បីទុកឲ្យឈ្មោះ [redacted] យីវឆាយ ទិញដីឲ្យកូនគាត់ឈ្មោះ [redacted] សារីជ័យ សួរវង្ស ចំពោះផ្ញើនៅព្រះសង្ឃប៉ុន្មាននោះខ្លួនពុំបានដឹងនោះទេ។ នៅថ្ងៃនោះឈ្មោះ ជ័យសួរវង្ស មិននៅទីនោះទេ។

៥-សាក្សីឈ្មោះ [redacted] សុខ បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ឈ្មោះ [redacted] សារី នេះខ្លួនស្គាល់ព្រោះគាត់ឧស្សាហ៍មកវត្តនិងត្រូវជាប្អូនលោក។ គាត់ចង់យកលុយផ្ញើចៅអធិការវត្តជង្រុក ដើម្បីទិញដីឲ្យកូនរបស់ឈ្មោះ [redacted]សារី ដែលនៅជាមួយលោក[redacted]ុន្នី។ ឈ្មោះ [redacted] សារី ឧស្សាហ៍មកធ្វើបុណ្យនៅវត្តចំពោះលុយដែលផ្ញើប៉ុន្មាននោះខ្លួនមិនដឹងនោះទេ។

០៦-សាក្សីឈ្មោះ [redacted]ឡេង បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ឈ្មោះ [redacted] សារី បានមកចូលរួមបុណ្យលោកតា [redacted] មុន្នី ហើយខ្លួនបានលឺដោយផ្ទាល់មាត់ពី[redacted]សារី ដែលយកប្រាក់មកផ្ញើ

និងលោក [redacted] មុន្នី ដើម្បីទុកលុយទិញដីឲ្យកូនរបស់គាត់។ ឈ្មោះ [redacted] សារី ខ្លួនស្គាល់គាត់ ដោយសារគាត់មកធ្វើបុណ្យ ណាមួយគាត់ត្រូវជាប្អូនរបស់លោកតា [redacted] មុន្នី។

០៧-សាក្សីឈ្មោះ [redacted] សុខា បានឆ្លើយបំភ្លឺថាៈ ខ្លួនលឺឪពុករបស់ក្មួយប្រុសឈ្មោះ [redacted] សារី និយាយនៅថ្ងៃបុណ្យថាគាត់យកលុយមកផ្ញើទិញដីឲ្យកូនគាត់ហើយខ្លួនមិនដឹងថាគាត់យកមកផ្ញើនិងនរណាគេនោះទេ។

០៨-សាក្សីឈ្មោះ [redacted] សុរុន បានបំភ្លឺថាៈ ខ្លួនបានលឺលោក [redacted] សារី ផ្ញើលុយនិងព្រះអង្គ [redacted] មុន្នី តែផ្ញើប៉ុន្មាននោះខ្លួនមិនដឹងនោះទេ ដោយនៅថ្ងៃនេះមានកម្មវិធីបុណ្យកឋិនទាន។ ខ្លួនស្គាល់ឈ្មោះ [redacted] ថាន់, [redacted] សារី, ម្តាយរបស់ហុក យីវឆាយ និងប៉ុន្មាននាក់ទៀតមើលមិនច្បាស់នោះទេ។

០៩-សាក្សីឈ្មោះ [redacted] ស្មាន់ បានឆ្លើយបំភ្លឺថាៈ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤ ឈ្មោះ [redacted] យីវឆាយ បានមកយកលុយពីលោកតា [redacted] មុន្នី ដែលជាព្រះចៅអធិការវត្តជង្រុក មូលហេតុដែលខ្លួនបានដឹងគឺដោយសារតែខ្លួនបានទៅជាមួយឈ្មោះ [redacted] យីវឆាយ ផ្ទាល់ ដោយពេលនោះលោកគាត់ក៏បានមានពុទ្ធិកាថា លុយនេះគឺជាលុយរបស់ប្អូនលោកទេ ផ្ញើទុកនៅនឹងគាត់ដើម្បីទិញដីឱ្យទៅកូនរបស់គាត់ឈ្មោះ [redacted] សារីជ័យសួរវង្ស នៅពេលរៀនចប់ ដែលត្រូវជាក្មួយរបស់លោកដែរ ពេលដែលលោកប្រគល់លុយឱ្យទៅឈ្មោះ [redacted] យីវឆាយ នោះគឺចំនួន ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក។ ពេលដែលទទួលបានលុយពីលោករួច នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ ឈ្មោះ [redacted] យីវឆាយ បានយកលុយនោះទៅប្រគល់ឱ្យទៅម្ចាស់ដីឈ្មោះ [redacted] សំណាង គ្រប់ចំនួន នៅផ្ទះរបស់ឈ្មោះ [redacted] យីវឆាយ ហើយដីដែលទិញនោះ មានទីតាំងស្ថិតនៅភូមិតាយីវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្នុងតម្លៃ ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ដោយបានធ្វើលិខិតទិញលក់ និងផ្ទេរសិទ្ធនៅសាលាឃុំ ជង្រុង មកឱ្យឈ្មោះ [redacted] យីវឆាយ ផងដែរ។ ក្រោយមកពេលដែលឈ្មោះ [redacted] សារីជ័យសួរវង្ស បានមកសុំផ្ទេរសិទ្ធិពីឈ្មោះ [redacted] យីវឆាយ វិញ តែឈ្មោះ [redacted] យីវឆាយ មិនព្រមផ្ទេរសិទ្ធិឱ្យឈ្មោះ [redacted] សារីជ័យសួរវង្ស វិញឡើយ ។ ចំពោះឈ្មោះ [redacted] យីវឆាយ យកលុយពីលោកតា [redacted] មុន្នី ប៉ុន្មានដងនោះខ្លួន មិនបានដឹងច្បាស់ទេ តែខ្លួនបានទៅយកលុយជាមួយ គាត់បានពីរដង គឺលើកទីមួយចំនួន ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក យកទៅទិញដីពីឈ្មោះ [redacted] សំណាង ស្ថិតនៅភូមិតាយីវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងលើកទី២ ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក តែមិនស្គាល់ម្ចាស់ដីឈ្មោះអីទេស្ថិតនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ចំពោះរឿងហេតុផ្សេងទៀតខ្លួនមិនបានដឹងទេ។

១០-សាក្សីឈ្មោះ [redacted] ឡូរីន បានឆ្លើយបំភ្លឺថាៈ ការទិញដីនេះខ្លួនមិនដឹងនោះទេ តែដីនៅភូមិបាក់ក គឺមានតម្លៃចំនួន ២៤០០០ដុល្លារ ដោយខ្លួនទិញជាមួយបងប្រុសឈ្មោះ [redacted] អោក និងឈ្មោះ វណ្ណី នៅក្នុងឆ្នាំ ២០១៦ ដោយមានចំណែកលុយខ្លួនចំនួន ៦០០០ដុល្លារ។ លោក [redacted] ស្មាន់ ជាសាក្សីក្នុងការទិញដីដែរគឺគ្រួសារ [redacted] យីវឆាយ ជាអ្នកទិញដីឲ្យហើយដីនេះលក់បាត់ហើយ។ ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] យីវឆាយ។ ខ្លួនសូមបញ្ជាក់ថា ដីដែលទិញតម្លៃ ២៤០០០ដុល្លារនេះគឺជាក់ឈ្មោះខ្លួននិងប្តីឈ្មោះ [redacted] យីវឆាយ។ ចំពោះការទិញដីរបស់ប្តីខ្លួនជាមួយនិងបងប្រុសខ្លួន ដែលទិញបានប៉ុន្មានដងនោះខ្លួនមិនចាំទេ ពេលដែលទិញដីតម្លៃ២៤០០០ដុល្លារនោះ គឺជាក់ឈ្មោះតែក្រុមគ្រួសារខ្លួនតែប៉ុណ្ណោះព្រោះបងប្រុសគាត់ជាបម្រើការ



Scanned with CamScanner

(Doctor) គ្មានពេលសៅរ៍អាទិត្យនោះទេ។ ក្នុងឯកសារទិញលក់ និងមានសាក្សីនរណានោះខ្លួនមិនចាំទេព្រោះទិញយូរហើយណាមួយដីនោះលក់ទៅវិញហើយ។ ចំពោះការពាក់ព័ន្ធរឿងដីជាមួយនរណានោះខ្លួនមិនដឹងនោះទេគឺទើបតែដឹងនៅពេលដែលគេដាក់ពាក្យបណ្ដឹងមកតុលាការ។ ពេលដឹងរឿងហើយនោះខ្លួនមិនបានសួរនាំនោះទេព្រោះខ្លួនដឹងថាលុយទិញដីនោះបានមកពីលុយរបស់ខ្លួនមួយចំណែកគឺចំនួន ៦០០០ដុល្លារ និងលុយរបស់បងប្រុសមួយចំណែកគឺចំនួន ១៨០០០ដុល្លារ។

១១-សាក្សីឈ្មោះ [redacted] ធីវយីវ បានឆ្លើយបំភ្លឺថាៈ ខ្លួនត្រូវជាម្ដាយបង្កើតមិនដែលមកលេងខ្មែរទេ។ ទើបមកតុលាការពីរដង។ ឈ្មោះ [redacted] មុន្នី ត្រូវប្អូនរបស់ខ្លួនបង្កើតមកលេងវត្តច្រើនដងហើយ។ ឈ្មោះ [redacted] យីវឆាយ ជាប្អូនជីដូនមួយនិងលោក [redacted] មុន្នី។ ចំពោះការប្រគល់លុយនោះខ្លួនមិនបានដឹងនោះទេ ព្រោះខ្លួនមកលេងកូន។

១២-សាក្សីឈ្មោះ [redacted] សល់ បានឆ្លើយបំភ្លឺថាៈ ខ្លួនជាខ្មែរនៅវៀតណាម ខ្លួនបានផ្ដិតមេដៃនៅវៀតណាមគឺឈ្មោះ ស្មាត ជាអ្នកយកទៅផ្ដិតនៅវៀតណាម ខ្លួនចេះតែផ្ដិតមេដៃទេ ហើយការផ្ដិតមេដៃនេះក៏មិនមានរឿងអ្វី ដែរខ្លួនមកលេងនៅស្រុកខ្មែរបានបីដងដែរ។

១៣-សាក្សីឈ្មោះ [redacted] រ៉េន បានឆ្លើយបំភ្លឺថាៈ ខ្លួនអត់ដឹងរឿងអ្វីទេ។ ខ្លួនចង់បំភ្លឺថា ដីខ្លួនទិញមិនមែនដីរបស់ខ្លួនទេ ខ្លួនជាឱពុកក្មេកដោយបានឲ្យលុយទៅកូនចំនួន ៥១៥០០ដុល្លារ។ ប្រពន្ធខ្លួនលក់ខោអាវ ខ្លួនបានទៅទិញដីកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ ដោយទិញដីពីឈ្មោះ [redacted] សំណាង ដោយខ្លួនគិតថាថ្ងៃក្រោយដាក់ឈ្មោះកូនដដែលទើបដាក់ឈ្មោះកូនតែម្ដងទៅ។

១៤-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សំណាង បានឆ្លើយបំភ្លឺថាៈ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ ឈ្មោះ [redacted] សាវីជ័យ សួរវង្ស ដែលជាដើមបណ្ដឹង បានទាក់ទងជាមួយនឹងអាជ្ញាធរ ដើម្បីមកធ្វើសាក្សីក្នុងការផ្ទេរកម្មសិទ្ធិដីហើយក្នុង នាមខ្លួនជាអ្នកតំណាងឱ្យអាជ្ញាធរស្រុកក៏បានទៅជួបជុំគ្នានៅផ្ទះឈ្មោះ [redacted] យីវឆាយ តែពេលនោះមិនបានជួប ឈ្មោះ [redacted] យីវឆាយ ទេជួបតែឪពុកក្មេករបស់គាត់ ហើយពួកខ្លួនក៏បាននិយាយជាមួយនឹងគាត់ដោយប្រាប់ថាពួកខ្លួនជាអាជ្ញាធរហើយ មកតាមការសំណូមពររបស់ឈ្មោះ [redacted] សាវីជ័យសួរវង្ស ដើម្បីធ្វើជាសាក្សីក្នុងការផ្ទេរកម្មសិទ្ធិពីឈ្មោះ [redacted] យីវឆាយ ទៅឈ្មោះ [redacted] សាវីជ័យសួរវង្ស ពេលនោះឈ្មោះ [redacted] យីវឆាយ មកដល់ហើយបាននិយាយថា មិនអាចផ្ទេរសិទ្ធិឱ្យទៅឈ្មោះ [redacted] សាវីជ័យសួរវង្ស ទេព្រោះដីនោះគឺជាដីដែលឪពុកក្មេកគាត់អ្នកឱ្យលុយទៅទិញ ពេលនោះឈ្មោះ [redacted] សាវីជ័យសួរវង្ស បានជជែកគ្នាហើយពេលនោះ ខ្លួនក៏បានសួរទៅឈ្មោះ [redacted] យីវឆាយ ថាចុះលុយដែលលោកតាព្រះនាម [redacted] មុន្នី ព្រះចៅអធិការវត្តជង្រុក ឱ្យទៅទិញដីនោះបានទៅទិញដីអត់ ប៉ុន្តែឈ្មោះ [redacted] យីវឆាយ ទទួលស្គាល់ថាបានយកលុយពីលោកប្រាកដមែន ដែលមានចំនួន ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិកដោយទូលប្រាប់លោកថាទៅទិញដី លុះពេលយកលុយបានមកដល់ផ្ទះឪពុកក្មេកគាត់បានសួរថា បានលុយមកពីណាដោយឈ្មោះ [redacted] យីវឆាយ បានប្រាប់ថា លុយនោះយកពីលោកហើយឈ្មោះ [redacted] យីវឆាយ បានប្រាប់ខ្លួនថាឪពុកក្មេកគាត់មិនឱ្យយកទេ ព្រោះលុយលោកជាលុយបុណ្យ ហើយឈ្មោះ [redacted] យីវឆាយ ក៏មិនបានយកលុយនោះទៅឱ្យលោកវិញដែរ ដោយនិយាយប្រាប់ខ្លួនថាបានយកលុយលោកទៅលេងភាគហ៊ុនវដ្ដករទឹកចាញ់



Scanned with CamScanner

អស់ហើយរួចក៏មិនបានទៅទូលប្រាប់លោកអ្វីដែរដោយខ្លាចលោកខឹង។ ខ្លួនបានដឹងរឿងនេះ តែត្រឹមប៉ុណ្ណឹង ចំណែកពាក់ព័ន្ធលុយដែលលោកតា [redacted] មុន្នី ឱ្យទៅឈ្មោះ [redacted] យីវឆាយ បានមកពីណានោះគឺមិនបាន ដឹងនោះទេ។ ខ្លួនស្គាល់លោកតា [redacted] មុន្នី ជាយូរមកហើយប្រហែលជាង ២០ឆ្នាំហើយ ចំពោះឈ្មោះ [redacted] យីវឆាយ គឺមិនដែលបានស្គាល់ទេ ហើយក៏មិនចាប់អារម្មណ៍ថាគាត់ធ្លាប់បួលជាព្រះសង្ឃនៅទីនោះពីមុនដែរ។

១៥-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] អ៊ោក បានឆ្លើយបំភ្លឺថា: ចំពោះរឿងហេតុដែលមាន ការចោទប្រកាន់ទៅលើឈ្មោះ [redacted] យីវឆាយ ពីរឿងរំលោភលើទំនុកចិត្តនោះ ខ្លួនមិនបានដឹងទេ កន្លងមកខ្លួន មិនដែលស្គាល់ឈ្មោះ [redacted] យីវឆាយ ទេ ប៉ុន្តែក្រោយពេលដែលគាត់មកទិញដីខ្លួន ទើបខ្លួនស្គាល់គាត់។ ខ្លួនធ្លាប់ បានលក់ដី២០ម៉ែត្រ ឱ្យទៅឈ្មោះ [redacted] យីវឆាយ តែមិនចាំថានៅក្នុងឆ្នាំណាទេ ដែលមានទីតាំងស្ថិតនៅភូមិ បាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្នុងតម្លៃ ២៤,០០០ (ពីរម៉ឺនបួន ពាន់) ដុល្លាអាមេរិកហើយ បានធ្វើលិខិតទិញលក់ និងផ្ទេរសិទ្ធិទៅឱ្យឈ្មោះ [redacted] យីវឆាយ នៅភូមិបាក់ក ដោយមានភូមិឃុំដឹងឮត្រឹមត្រូវ ផងដែរ។ ក្នុងពេលដែលឈ្មោះ [redacted] យីវឆាយ មកទិញដីគឺតាមរយៈមិត្តភក្តិឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៥០ឆ្នាំ រស់នៅភូមិតាងៅ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាអ្នកនាំមក ហើយខ្លួនមិនបានដឹងថា ឈ្មោះ [redacted] យីវឆាយ គាត់ទិញដីនោះយកទៅឱ្យអ្នកណាឬលក់បន្តទៅឱ្យអ្នកណាក៏មិនបានដឹងដែរ។ ចំពោះរឿង ហេតុនេះខ្លួនបានដឹងតែប៉ុណ្ណឹងទេ ។

១៦-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] វ៉ាន់ឌី បានឆ្លើយបំភ្លឺថា: ចំពោះរឿងហេតុដែលមាន ការចោទប្រកាន់ទៅលើឈ្មោះ [redacted] យីវឆាយ ពីរឿងរំលោភលើទំនុកចិត្តនោះខ្លួនមិនបានដឹងទេ កន្លងមកខ្លួន និងប្តីធ្លាប់បានលក់ដី២០ម៉ែត្រ ឱ្យទៅឈ្មោះ [redacted] យីវឆាយ តែមិនចាំថានៅក្នុងឆ្នាំណាទេ ដែលមានទីតាំងស្ថិត នៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្នុងតម្លៃ ២៤,០០០ (ពីរម៉ឺនបួនពាន់) ដុល្លាអាមេរិកហើយ ខ្លួននិងប្តីឈ្មោះ [redacted] អ៊ោក បានធ្វើលិខិតទិញលក់ និងផ្ទេរសិទ្ធិទៅឱ្យឈ្មោះ [redacted] យីវឆាយ នៅភូមិបាក់កដោយ មានភូមិឃុំដឹងឮត្រឹមត្រូវផងដែរ។ កន្លងមកមិនដែលស្គាល់ឈ្មោះ [redacted] យីវឆាយ ទេ ទើបតែស្គាល់នៅពេល ដែលគាត់មកទិញដី ហើយចំពោះដីនោះ គាត់ទិញឱ្យអ្នកណាបន្តទៀតក៏មិនបានដឹងដែរ។ ចំពោះរឿងហេតុនេះ ខ្លួនដឹងតែប៉ុណ្ណឹងទេ។

១៧-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សារុន បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ឈ្មោះ [redacted] សារី បានមកចូលរួមបុណ្យលោកតា [redacted] មុន្នី ហើយបានប្រាប់ខ្លួនដែលជាចាស់ទុំក្នុងវត្តថាគាត់ បានទុកលុយចំនួន ៩៥,០០០ (ប្រាំបួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទុកឱ្យលោកតារកទិញដីឱ្យកូនប្រុសគាត់ ឈ្មោះ [redacted] សារីជ័យ សួរវង្ស ចំពោះរឿងហេតុនេះខ្លួនដឹងតែប៉ុណ្ណឹងទេ។

១៨-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សារ៉េត បានឆ្លើយបំភ្លឺថា: ខ្លួនស្គាល់ឈ្មោះ [redacted] យីវឆាយ តាមរយៈឈ្មោះ [redacted] ស្មាន់ នៅពេលចូលប្រាក់គ្នាទិញដីមួយកន្លែង។ ដីនោះតម្លៃ ១០៣,០០០ (ដប់ម៉ឺនបី ពាន់)ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ស្មាន និងឈ្មោះ [redacted] យីវឆាយ គ្មានប្រាក់គ្រប់ ក៏បបួលខ្លួនទិញ ដោយចូលលុយគ្នា ម្នាក់ពាក់កណ្តាល ហើយបែងចែកដីជាពីរចំណែកស្មើគ្នា តែប្រើប្រាស់ឯកសារជាយឡែក ពីគ្នាពេលទៅមើលដីនោះ បងប្រុសខ្លួនបានប្រាប់ឈ្មោះ [redacted] យីវឆាយ ថាប្រគល់ប្រាក់ថ្លៃដីនៃចំណែករបស់ខ្លួន

ឱ្យម្ចាស់ដី ឱ្យហើយទៅ តែឈ្មោះ [redacted] យីវឆាយ និយាយថា ចាំបានលុយផ្ញើពីស្រុកក្រៅមកចាំប្រគល់ប្រាក់ឱ្យម្ចាស់គេ។

១៩-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] មុន្នី បានឆ្លើយបំភ្លឺថា: ឈ្មោះ [redacted] យីវ ឆាយ ពិតជាបានមកយកប្រាក់ពីខ្លួន ចំនួនពីរលើកពិតមែន ដោយយកទៅទិញដីពីរកន្លែងនៅភូមិតាយីវ មួយកន្លែងតម្លៃ ៥១,៥០០ (ប្រាំម៉ឺនមួយពាន់ប្រាំរយ) ដុល្លាអាមេរិក និងមួយកន្លែងនៅភូមិបាក់ក តម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ដើម្បីយកទៅទិញដី ដោយមានឈ្មោះ [redacted] ស្មាន់ ដឹងឮ ហើយបានប្រាប់ឱ្យដាក់ឈ្មោះ [redacted] សារីជ័យសួរវង្ស ប៉ុន្តែឈ្មោះ [redacted] យីវឆាយ បែរជាដាក់ឈ្មោះខ្លួននិងប្រពន្ធទៅវិញ។

២០-មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសេចក្ដីសន្និដ្ឋានថា ៖ ក្នុងរឿងនេះដែលគឺមានមូល ដ្ឋានច្បាស់លាស់ និងភស្តុតាងត្រឹមត្រូវក្នុងការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពីបទរំលោភលើទំនុកចិត្ត ដែលមាននៅក្នុងប្បញ្ញត្តិមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់។ នីត្យានុកូល ឬធាតុច្បាប់ដែលមានចែងក្នុងមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនិងបទរំលោភលើទំនុកចិត្ត ពាក់ព័ន្ធនិងធាតុសត្យានុម័តនោះគឺអំពើឃើញថារឿងអង្គហេតុនេះលោក [redacted] យីវឆាយ គាត់មិនទទួល ស្គាល់ថាគាត់មិនបានយកលុយនោះទេ គាត់សុខចិត្តទទួលខុសត្រូវចំពោះមុខច្បាប់ ហើយគាត់បាននិយាយថា មិនស្គាល់ព្រះតេជគុណសាន មុន្នី។ តាមពិតទៅលោក [redacted] មុន្នី ជាសង្ឃរាជវត្ត ដោយលោកហុក យីវឆាយ បានមកបួសរៀនសិក្សានៅវត្ត។ លោកតា [redacted] មុន្នី ទុកចិត្តលើលោក [redacted] យីវឆាយ ពេលណាដែលលោក មិននៅគឺលោកតែងតែប្រគល់កិច្ចកបិនទាន និងត្រៃជាដើមជំនួសលោក ដោយសារតែការជឿទុកចិត្ត និងការប្រគល់កិច្ចការមួយចំនួនដោយពុំបានធ្វើលិខិតស្នាម ដោយជាក្រុមគ្រួសាររបស់គាត់។ បើពាក់ព័ន្ធលិខិតស្នាមហេតុអីបានជាគាត់មិនចោទប្រកាន់អ្នកដទៃ បែរចោទតែឈ្មោះ [redacted] យីវឆាយ ដោយសារតែគាត់ជាក្មួយបង្កើតឈ្មោះ [redacted] សារី ជាឪពុករបស់ឈ្មោះ [redacted] សារីជ័យសួរវង្ស ដែលរស់នៅកម្ពុជាក្រោម ដោយលោក [redacted] សារី ឃើញថាដីឡើងថ្លៃ និងបង្កបង្កើនផលល្អ ណាមួយដីស្រុកខ្មែរឡើងថ្លៃហើយគាត់ចង់បានដី។ ឈ្មោះ [redacted] សារី ជ័យសួរវង្ស ទើបតែមានអាយុលើស ១៨ឆ្នាំមករៀននៅភ្នំពេញបាត់ៗអត់ដឹងអីទេ ហើយលោក [redacted] យីវឆាយ ទើបតែសឹក និងការប្រពន្ធ។ គាត់បានប្រគល់កិច្ចការរឿងទិញដីឲ្យលោកហុក យីវឆាយ ព្រោះលុយគេបានផ្ញើមកឲ្យចំនួន ៩៥០០០ដុល្លារ (ប្រាំបួនម៉ឺនប្រាំពាន់ដុល្លារ)។ លោក [redacted] យីវឆាយ រកបានដីមួយកន្លែងនៅភូមិកាយីវ និងទូលព្រះតេជគុណថា គេមានដីដោយគេលក់តម្លៃប៉ុន្មាននេះៗ ទិញចែកគ្នា និងបានយកលុយពីលោកទៅទិញដីនោះ។ លើកទី២ នៅភូមិបាក់ក តម្លៃដីនោះដូចនៅក្នុងកិច្ចសន្យាទិញលក់ សួរថាហេតុអីពេលនោះមិនដាក់ឈ្មោះ [redacted] សារីជ័យសួរវង្ស តែម្ដងទៅ។ មូលហេតុដែលដឹងនោះគឺដោយសារការលក់ដីគឺមានការផ្ទេរសិទ្ធិ ហើយណាមួយសុទ្ធតែកូនចៅឯងមិនទៅណានោះទេ ដល់ពេល ថ្ងៃកម្មវិធីបុណ្យមិនឃើញ [redacted] យីវឆាយ មក ហើយលោក [redacted] សារី សង្ស័យ និងបានសួរដេញដោលរឿងដី ហើយ [redacted] សារីជ័យសួរវង្ស បាននិយាយឲ្យផ្ទេរឈ្មោះតែ [redacted] យីឆាយ ថាទេ បើមកតែម្នាក់ឯង។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ [redacted] សារីជ័យសួរវង្ស បានហៅអាជ្ញាធរមូលដ្ឋាន និងតំណាងស្រុក ដោយលោក [redacted] យីវឆាយ និយាយថាដីនេះជាដីរបស់គាត់ ដីដែលរកទិញឲ្យឯងនោះមិនបានទិញទេ គឺគាត់បានយកលុយនោះទៅលេងភាគហ៊ុនអស់ហើយ តែគាត់បាននិយាយថាបានយកលុយនិងមែន ដែលមានចំនួនទឹកប្រាក់ ១១៥០០ដុល្លារ ដោយមិនបានទិញដី តែនៅចំពោះ មុខតំណាងអយ្យការគាត់ឆ្លើយថា គាត់មិនមែនជាដីគាត់ទេ បើតុលាការរកឃើញគាត់សុខចិត្តទទួលទោស នៅចំពោះមុខចៅក្រមស៊ើបសួរគាត់ឆ្លើយថា ចម្លើយទាំងអស់ជាចម្លើយរបស់គាត់មែន តែសំដីគាត់នៅពេលនោះ គឺគាត់ខឹងដាក់តែប៉ុណ្ណោះ។ ចម្លើយទាំងពីរដំណាក់កាលនេះគឺមានការប្រែប្រួលដែលធ្វើឲ្យយើងឃើញថា គឺមានចេតនាទុច្ចរិត។ យោងតាមអង្គហេតុ និងអង្គច្បាប់ដូចដែលបានរៀបរាប់ខាងលើរួចមកសបញ្ជាក់ឲ្យឃើញថាទាំងសាក្សី និងភស្តុតាងដូចដែលបានរៀបរាប់ខាងលើមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់សុំឲ្យតុលាការសម្រេចធ្វើការចោទប្រកាន់ និងផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពីបទៈ រំលោភលើទំនុកចិត្ត ដែលមានចែងក្នុងប្បញ្ញត្តិមាត្រា៣៩១, ៣៩២ និងសុំចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទរូបនេះ និងសុំទាមទារសំណងការខូចខាតដូចនៅក្នុងពាក្យបណ្ដឹងចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ចំនួន ១០០,០០០ដុល្លារ (ដប់ម៉ឺនដុល្លារអាមេរិកគត់) របស់កូនក្ដីខ្លួន។



Scanned with CamScanner

២១-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានពិនិត្យសំណុំរឿងលេខ ៣៣៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីជ័យសួរវង្ស និងបានស្តាប់ចម្លើយសាក្សីមួយចំនួននៅក្នុងសវនាការនេះ តំណាងអយ្យការយល់ឃើញថា អង្គហេតុនេះដែលកើតក្នុងអំឡុងឆ្នាំ២០១៤ គឺមានទំនាក់ទំនងរវាងលោក [redacted] យីវឆាយ និងលោក [redacted] សារី និងព្រះតេជគុណ [redacted] មុន្នី ពិតជាមានទំនាក់ទំនងនិងអង្គហេតុមួយដែលផ្តើមចេញពីទំនាក់ទំនងគ្រួសារ ណាមួយនៅក្នុងអង្គហេតុនេះសុទ្ធតែជាក្រុមគ្រួសារជិតដិតតែម្តង។ ម្យ៉ាងវិញទៀតលោក [redacted] យីវឆាយ ជាបុគ្គលដែលបានស្នាក់អាស្រ័យនៅជាមួយនិងព្រះសង្ឃ [redacted] មុន្នី និងបានសឹក ហើយរៀបចំគូរស្រករ ក្នុងបែបនៃព្រះពុទ្ធសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រជាជនភាគរយគោរពនិងស្រឡាញ់ ហើយឲ្យតម្លៃទៅលើពុទ្ធសាសនា និងឲ្យតម្លៃទៅលើបុគ្គលដែលមានឋានជាព្រហសង្ឃ ម្យ៉ាងវិញទៀតទោះបីជាបុគ្គលមួយចំនួនដែលបានលាចាសក្ខាបទក៏ដោយ ក៏ទទួលបាននាមជាអន្និត ជាបណ្ឌិត និងក្រោយមកត្រូវបានរៀបចំគូស្រករពីសំណាក់ប្រជាពលរដ្ឋ។ ក្នុងន័យនេះគឺជាការចាប់អារម្មណ៍មួយដែលថា បុគ្គលមួយដែលមានតម្លៃ គឺនៅពេលដែលគាត់ធ្វើសកម្មភាពអ្វីមួយអាចបង្វែរគាប់ភ្នែកមនុស្សមួយចំនួនធំតែម្តង ពោលគឺមិនចាប់អារម្មណ៍ចេតនាបែបស៊ីជម្រៅរបស់បុគ្គលនោះឡើយ។ ម្យ៉ាងវិញទៀតនៅក្នុងអង្គហេតុនេះគឺសុទ្ធតែទំនាក់ទំនងរវាងពូក្មួយសាច់ញាតិផ្ទាល់ៗតែម្តង ព្រោះរាល់ការធ្វើអ្វីក៏ដោយគឺឈរលើឆន្ទៈនៃការជឿជាក់ និងពាក់ព័ន្ធនិងការប្រគល់និងទទួលប្រាក់ជាកិច្ចសន្យាមួយដែលឈរលើគោលការណ៍ពីរ លក្ខខណ្ឌទម្រង់ ហើយលក្ខណ្ឌគ្រឹះនិយាយពីអី? មនុស្សពីរនាក់ចូលចិត្តគ្នាមានឆន្ទៈរួមគ្នាក្នុងការធ្វើអ្វីមួយ ដូចក្នុងករណីដែលលោក [redacted] សារី គាត់ផ្ញើលុយទៅនិងព្រះសង្ឃ ដោយគ្មានការធ្វើកិច្ចសន្យា គឺបានបង្ហាញថាមនុស្សពីរនាក់គឺមានទំនាក់ទំនងអ្វីមួយជាមួយគ្នា។ ប៉ុន្តែគួរពិចារណាថា កិច្ចសន្យាគឺមានលក្ខខ័ណ្ឌពីរ ហើយលក្ខខណ្ឌដែលមុតស្រួចបំផុតគឺលក្ខខ័ណ្ឌទម្រង់ ហើយលក្ខខណ្ឌនេះឈរទៅលើឆន្ទៈម្យ៉ាងវិញទៀត សំណួរសួរថា វត្តមានរបស់ព្រះតេជគុណសាន មុន្នី ក្នុងឋានៈដែលគាត់ជាព្រះសង្ឃ សួរថាតើលោក [redacted] សារី ក្រៅពីព្រះតេជគុណគាត់មិនមែនអត់សាច់ញាតិទេ ប៉ុន្តែព្រះតេជគុណក្នុងឋានៈជាសង្ឃជាគោលការណ៍ ជាអារម្មណ៍ និងជំនឿពុទ្ធសាសនា ជឿជាក់ណាក់ថាព្រះសង្ឃមិនកុហកបោកប្រាស់នេះហើយដែលធ្វើឲ្យលោក [redacted] សារី ជឿជាក់បំផុត ទីមួយគាត់នៅក្នុងឋានៈជាសាច់ញាតិ ទីពីរព្រះអង្គជាសង្ឃ ក្នុងការផ្ញើលុយទៅនិងព្រះអង្គ ម្យ៉ាងវិញទៀតមិនមានកិច្ចសន្យាប្រគល់លុយ ៩៥០០០ ដុល្លារ ពីលោក [redacted] សារី ទៅព្រះតេជគុណ [redacted] មុន្នី នេះជារឿងដែលល្អ។ ក្នុងឋានៈជាសង្ឃលុយចាត់ចែងអ្វីក៏ដោយត្រូវបិតនៅក្នុងក្រមខណ្ឌគណកម្មាធិការអាចារ្យវត្ត ចុះប្រសិនបើការធ្វើនេះក្នុងក្របខណ្ឌមួយដែលការពារខ្លួនប្រាកដជាបកស្រាយថា នៅពេលដែលគាត់ប្រើលុយចំនួន ៩៥០០០ដុល្លារ ទៅឲ្យនរណាម្នាក់ចាយវាយដែលគាត់ទទួលពីលោក [redacted] សារី ពេលនោះគណៈកម្មាធិការអចារ្យប្រាកដជារករឿងព្រះអង្គ អាចជាលុយកឋិនទាន អាចជាលុយកសាងវត្ត នេះហើយបានជាមានការទទួលលុយជាលាយលក្ខណ៍អក្សរ ហើយតំណាងអយ្យការមិនពិចារណាទៅលើសាក្សីនោះទេ កិច្ចសន្យាកើតចេញពីឆន្ទៈរវាងគូភាគី ហើយសាក្សីគ្រាន់តែជាអ្នកបានដឹង និងបានលឺ ហើយគុណភាពសាក្សីអង្គសវនាការទទួលស្គាល់ថាអ្នកដែលមកធ្វើសាក្សីក្រោយប៉ុន្មាននាក់នេះគឺសុទ្ធតែសាច់ញាតិរបស់ជនជាប់ចោទ និងសុំឲ្យអង្គសវនាការពិចារណាទៅលើសាក្សី អ្វីដែលតំណាងអយ្យការយល់ឃើញនោះគឺជារឿងត្រឹមត្រូវដែលគាត់មានកិច្ចសន្យាជាមួយព្រះសង្ឃ។ ប្រសិនបើគ្មានកិច្ចសន្យានោះទេ ការវាយតម្លៃទៅលើព្រះអង្គដោយប្រើប្រាស់លុយខុសគោលដៅ សំណួរសួរថា តើព្រះអង្គឬព្រះសង្ឃ រកលុយឯណា ព្រោះមានចំណូល ចំណាយច្រើនណាស់ក្នុងការបង់ពន្ធដើម្បីព្រះអង្គទទួល ឬដើម្បីចំណាយផ្សេងៗ ដោយឡែកបើពាក់ព័ន្ធនិងថវិការ កឋិន ឬថវិការផ្សេងៗ នេះជាការដែលត្រឹមត្រូវដែលមានលិខិតប្រគល់ទទួលលុយរវាងលោក [redacted] សារី ជាមួយនិងព្រះអង្គ។ ក្នុងទំនាក់ទំនងរវាងលោក ហ៊ុក យីវឆាយ ក្នុងការទៅទំនាក់ទំនងជាមួយព្រះសង្ឃ និងការស្វាត់ស្វែងទៅរកដីដែលលើផែនការណ៍ដែល [redacted] សារី ដែលមានគោលបំណងនេះគឺច្បាស់ហើយស្អិតរមួតណាមួយសុទ្ធតែសាច់ញាតិ។ ការបង់លុយជាបន្តបន្ទាប់មានពីរ



Scanned with CamScanner

ដំណាក់កាលហើយមានភាពស៊ីសង្វាក់ត្រង់ លើកទី១ ទឹកប្រាក់ចំនួន ៥១៥០០ដុល្លារ ដែលមានអង្គហេតុថា លោក [redacted] យីវឆាយ ជាមួយលោក [redacted] ស្មាន់ ដែលបានទទួលប្រាក់ពីព្រះអង្គសាន មុន្នីចំនួន ៥១៥០០ដុល្លារ ដើម្បីទិញដី ហើយមានភាពស៊ីសង្វាក់គ្នាអំពីអង្គហេតុថា ពិតជាមានការទិញដីមែន គឺទិញដីនៅភូមិកាយីវ ឃុំជង្រុក ពីម្ចាស់ដីដើមឈ្មោះ [redacted] សំណាង អង្គហេតុនេះគឺមានភាពស៊ីសង្វាក់គ្នាមានការទទួលលុយ និងមានការលក់ទិញ បន្ទាប់មកទៀតមានការប្រគល់លុយលើកទី២ រវាងលោក [redacted] យីវឆាយ , [redacted] ស្មាន់ ជាមួយព្រះតេជគុណ [redacted] មុន្នី ចំនួនទឹកប្រាក់ ៣០០០០ដុល្លារ ដែលមានភាពស៊ីសង្វាក់គ្នាមានការទិញដីនៅភូមិបាក់កក្ដុង តម្លៃ២៤០០០ដុល្លារ ក្នុងរង្វង់ទឹកប្រាក់ចំនួន ៣០០០០ដុល្លារ ដោយប្រើប្រាស់លុយត្រឹមតែ ២៤០០០ដុល្លារ គឺសមហេតុសមផល។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ មានកម្មវិធីបុណ្យមួយ និងមានការប្រគល់លុយពីលោក [redacted] សារី ទៅព្រះតេជគុណ [redacted] មុន្នី ហើយមានសាក្សីមួយចំនួនបានឆ្លើយអំពីកាសន្ទនាគ្នា ដោយលោក [redacted] សារី មានបំណងផ្ញើលុយតែមិនដឹងថាលុយប៉ុន្មាននោះទេ។ តែមានអង្គហេតុដែលលោក [redacted] សារី បាននិយាយថានិងផ្ញើប្រាក់មួយចំនួននៅព្រះអង្គដើម្បីទិញដី។ សាក្សីមួយចំនួនបានឆ្លើយអំពីអង្គហេតុនេះមុនពេលដែលផ្ញើលុយរវាងលោក [redacted] សារី ជាមួយនិងព្រះអង្គ [redacted] មុន្នី។ ម្យ៉ាងវិញទៀតក្រោយពីបានស្ដាប់អំណានចម្លើយដែលក្រឡាបញ្ជីសវនាការបានអាននោះជាកំណត់ហេតុចំពោះមុខភាគីពាក់ព័ន្ធ តាមអំណានចម្លើយរបស់ជនជាប់ឈ្មោះ [redacted] យីវឆាយ ដោយលោក [redacted] យីវឆាយ បានឆ្លើយបដិសេធនៅអង្គហេតុដែលខ្លួនថាខ្លួនបានទទួលលុយ តែឆ្លើយនៅចៅក្រមស៊ើបថាលុយដែលខ្លួនបានទទួលនោះគឺលេងភាគហ៊ុនរថ្នករទឹកចាញ់អស់ហើយ ទោះបីជា [redacted] យីវឆាយ យកលុយ ដែលទទួលបានពីព្រះអង្គ [redacted] មុន្នី យកទៅទិញដីចំគោលដៅក៏ដោយ ឬក៏លោក [redacted] យីវឆាយ ពិតជាយកលុយនោះទៅលេងល្បែង ឬក៏ចាញ់ដោយការលេងភាគហ៊ុនក៏ដោយ។ តើការយកលុយរបស់គេ ឬទទួលលុយពីគេដើម្បីទិញដីឲ្យម្ចាស់គេ ទោះបីជាយកលុយទៅទិញដីពីកន្លែងនិងជាលុយដែលប្រើប្រាស់ចំគោលដៅក៏ដោយ ប៉ុន្តែលោក [redacted] យីវឆាយ មានចេតនាទុច្ចរិតច្បាស់លាស់ក្នុងការគេចវេសផ្ទេសិទ្ធិទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ចម្លើយរបស់លោក [redacted] យីវឆាយ បានអះអាងថា ខ្លួនលេងចាញ់ភាគហ៊ុន នេះជាការប្រើប្រាស់លុយមិនចំគោលដៅពីគោលបំណងរបស់ម្ចាស់បណ្ដឹងរដ្ឋប្បវេណី។ ទោះបីជាហេតុផលលើកទី១ ឬលើកទី២ ក៏ដោយនូវការឆ្លើយរបស់លោក [redacted] យីវឆាយ គឺជាការដែលបំពានលើគោលបំណងនិងឆន្ទៈរវាងម្ចាស់លុយ និងលោក [redacted] យីវឆាយ។ ជាពិសេសនៅក្នុងអង្គហេតុនេះសាក្សីដែលមានគុណវាទគុណវុធ ដោយគាត់មានគុណវុធទីមួយស្មើរនិងភាគីពាក់ព័ន្ធគាត់គឺជាអ្នកកណ្ដាលទាំងដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ សំណួរសួថាតើគាត់មានផលប្រយោជន៍អ្វីក្នុងការដែលគាត់មិនឆ្លើយក្នុងលក្ខណៈកណ្ដាល ម្យ៉ាងវិញទៀតទាំងដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ គឺមិនដែលមានទំនាក់ទំនងអវិជ្ជមានជាមួយសាច់ញាតិខ្លួននោះទេ ម្យ៉ាងវិញទៀតឈ្មោះ [redacted] ស្មាន់ ជាសាក្សីតែមួយគត់ដែលបានចូលរួមក្នុងការទទួលលុយជាមួយ [redacted] យីវឆាយ ពីព្រះអង្គ [redacted] មុន្នី ទាំងពីរលើក ព្រមទាំងទៅរកដី។ ទាំងនេះសុំឲ្យអង្គសវនាការពិចារណាអំពីគុណភាពសាក្សី ដោយសាក្សីដែលត្រូវជាភរិយារបស់ជនជាប់ចោទ ក៏ដូចជាសាក្សីឪពុកក្មេក តំណាងអយ្យការស្នើសុំឲ្យអង្គសវនាការពិចារណាអំពីទំនាក់ទំនងមនោសញ្ចេតនា និងគុណភាពក្នុងឋានៈដែលគាត់ជាសាក្សីក្នុងការឆ្លើយដោះបន្ទុកលើជនជាប់ចោទ។ ម្យ៉ាងវិញទៅនៅក្នុងអង្គសវនាការ តំណាងអយ្យការចាប់អារម្មពីពីរដងទៅបីដង ដែលមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបដិសេធនូវឃ្លីបអាត់សម្លេងដែលមានការចូលរួមពីដំណាក់កាលព្រះរាជអជ្ញា តំណាងអយ្យការសុំឲ្យលោកមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទពិនិត្យទៅលើមាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការលុបមោឃភាពដោយដីកាដំណោះស្រាយ ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបឬមោឃភាពនីតិវិធីមុន ប្រសិនបើគ្មានមោឃភាពណាមួយនូវនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ ដូច្នេះតំណាងអយ្យការនៅតែរក្សាដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយប្ដឹងសុំឲ្យលោកចៅក្រមសម្រេចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពីបទ រំលោភលើទំនុកចិត្ត

តាមប្បញ្ញត្តិមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៤។

២២-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមការដេញដោល និងការសាក សួរនៅចំពោះមុខក៏ដូចនៅដំណាក់កាលពីដំណើរដំបូងនៃរឿងក្តីនេះ ខ្លួនសុំលើកចំណុចសំខាន់ៗមួយចំនួនពាក់ ព័ន្ធដើមចោទដែលប្តឹងកូនក្តីរបស់ខ្លួន ក្នុងនោះខ្លួនមើលឃើញភាពមិនប្រក្រតីតាំងពីចំណុចចាប់ផ្តើមនៃពាក្យ បណ្តឹងរបស់ឈ្មោះ [redacted] ជ័យសារីសួរវង្ស ដែលទទួលសិទ្ធិពីឪពុកក្នុងការតាំងខ្លួនមកធ្វើជាដើមបណ្តឹង និងធ្វើ សកម្មភាពបណ្តឹងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ ខ្លួនយល់ឃើញថាយោងតាមក្រមរដ្ឋប្បវេណីគឺមានតែមេធាវី ទេដែលមានសិទ្ធិធ្វើសកម្មភាពនៃបណ្តឹង។ ទោះបីជា [redacted] សារីជ័យសួរវង្ស មិនបានធ្វើសកម្មភាពផ្ទាល់ខ្លួនក៏ ដោយក៏ខ្លួនមិនមែនជាអ្នកតំណាងដែលមានសិទ្ធិក្នុងការធ្វើជាអ្នកតំណាងឡើយ ទោះបីជាមេធាវីទទួលសិទ្ធិក្នុង ការការពារសិទ្ធិរបស់គាត់ដោយគ្មានសិទ្ធិជាអ្នកតំណាងនោះ គឺមិនអាចយកជាការបានឡើយ។ ពាក់ព័ន្ធនិងភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនឈ្មោះ [redacted] យីវឆាយ នេះចាប់តាំងដំណាក់កាលដេញដោលចំពោះមុខ ដំណាក់កាលស៊ើបសួរ និងនៅដំណាក់កាលសភាពស៊ើបសួរ នៃសាលាឧទ្ធរណ៍ បានបញ្ជាក់យ៉ាងច្បាស់អំពីសាក្សី នីមួយៗគ្រាន់តែបានលឺ និងនិយាយតៗគ្នាពីមួយទៅមួយ ដោយគ្មានភស្តុតាងណាមួយច្បាស់លាស់ពិតប្រាកដ គ្មានសង្ស័យ សុទ្ធតែភស្តុតាងដែលមានភាពមិនប្រក្រតី។ យោងតាមមាត្រា ១នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់រដ្ឋកិច្ចនីតិវិធីទាំងអស់ត្រូវតែម៉ត់ចត់ច្បាស់លាស់ ហើយគ្មានការសង្ស័យ បើយើងក្រលែកទៅមើលមាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ជាក់យ៉ាងច្បាស់ដែល អង្គហេតុត្រូវមានភាពច្បាស់លាស់ទើបមានការ សម្រេចសេចក្តីដោយគ្មានការសោកស្តាយ លើសពីនេះទៀតសោតរាល់ការពាក់ព័ន្ធ និងយោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានការពារយ៉ាងដាច់ខាតដែលជាច្បាប់កំពូល និងការពារសិទ្ធិមិនឲ្យរំលោភលើ លំនៅដ្ឋាន អាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមទូរលេខ តាមទូគមនាគមន៍ តាមទូរស័ព្ទ ត្រូវបានធានាចុះ បើការស្តាប់សម្លេងទាំងអស់នេះធ្វើឡើងមុនពេលនៃការស៊ើបអង្កេតទាំងអស់ប្រៀបបីដូចជាការដាក់អន្ទាក់ ចំណុចមិនប្រក្រតីទីមួយអ្នកដែលគ្មានសិទ្ធិប្តឹងមកតាំងខ្លួនជាដើមបណ្តឹងមកប្តឹងកូនក្តីខ្លួនចាប់ដាក់គុកនេះហើយ ដែលជាចំណុមិនប្រក្រតី ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិស្នើសុំឲ្យតុលាការពិចារណាចំណុចសំខាន់ៗនៅ ចំណុចនោះ និងពាក់ព័ន្ធលិខិតប្រគល់សិទ្ធិឲ្យប្តឹងទៀតសោត ទោះបីជានៅក្នុងរឿងក្តីរដ្ឋប្បវេណីក៏មិនអាចតាំងខ្លួនជាដើមបណ្តឹងបានដែរ បានបើនៅក្នុងដរាបណាមានទឹកប្រាក់តិចជាងមួយលានរៀល។ ចាប់តាំងពីការដេញ ដោលនៅដំណាក់កាលចៅក្រមស៊ើបសួរកូនក្តីរបស់ខ្លួនបានឆ្លើយដោយគ្មានការប្រែប្រួលតាំងពីដំណាក់កាល ចំពោះមុខព្រះរាជអាជ្ញា តំណាក់កាលតទល់ តំណាក់កាលស៊ើបសួរ ហើយនៅក្នុងដំណាក់កាលស៊ើបសួរបើមាន ភស្តុតាងច្បាស់លាស់ពិតប្រាកដត្រឹមត្រូវ ហេតុអីបានជាចៅក្រមស៊ើបសួរមិនឃុំខ្លួនកូនក្តីខ្លួននៅពេលហ្នឹង។ ពាក់ព័ន្ធនិងបញ្ហាទាំងអស់និងយើងមើលទៅរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣៨ រាល់វិមតិសង្ស័យ ត្រូវបានផលប្រយោជន៍មកលើជនជាប់ចោទ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំបដិសេធ ពាក្យបណ្តឹងចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ និងពាក្យបណ្តឹងបន្ថែមចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សារីជ័យសួរវង្ស ចោលជាអាសាងបង់ និងឲ្យកូនក្តីខ្លួនឈ្មោះ [redacted] យីវឆាយ រួចខ្លួនពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ ២០១៤ ដែលជាបទល្មើសរំលោភលើទំនុកចិត្ត និងមានចែងឲ្យផ្តន្ទាទោសតាមប្បញ្ញត្តិមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ និងបញ្ឈប់អនុភាពដីកាបង្គាប់ឲ្យចាប់ខ្លួនឃុំខ្លួន លេខ ១៥៩/១៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍។

២៣-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ខ្លួនសុំបន្ថែមទៅលើសេចក្តីសន្និដ្ឋាន របស់សហភាតាដោយសាររឿងនេះគឺមានភាពមិនប្រក្រតីតាំងពីដំបូង លិខិតនេះ និងសាក្សីមួយចំនួនគាត់បាន និយាយថាធ្វើបុណ្យនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ ហើយលោក [redacted] ស្មាន់ គាត់ថាចាប់ផ្តើមធ្វើ



Scanned with CamScanner

លិខិតនេះជា លោក [redacted] សារី ជាមួយលោកចៅអធិការ [redacted] មុន្នី ប៉ុន្តែលិខិតនេះចុះនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤។

-ក្រោយពីបានស្តាប់អំណាចនចម្លើយឈ្មោះ [redacted] យីវឆាយ ជា ជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយឈ្មោះ [redacted] សារីជ័យសួរវង្ស ជា ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់សាក្សី និងបានស្តាប់អំណានចម្លើយរបស់សាក្សី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យកំណត់ហេតុឯកសារ ភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការខេត្តកំពង់ស្ពឺ

## យល់ឃើញថា ៖

១-តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សារីជ័យសួរវង្ស, តាមលទ្ធផលស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងលទ្ធផលនៃការសាកសួរដេញដោលនាពេលសវនាការ បានបង្ហាញឲ្យឃើញថា កាលពីអំឡុងឆ្នាំ២០១៤ មានអំពើកែបំបាត់ប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីផ្ញើទុកជាមួយព្រះសង្ឃព្រះនាម [redacted] មុន្នី ពិតប្រាកដមែន។

២-ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ បានឆ្លើយបដិសេធនូវគ្រប់ដំណាក់កាលថាខ្លួនមិនបានយកលុយពីព្រះសង្ឃ [redacted] មុន្នី នោះទេ។ ចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពុំមានភស្តុតាងបញ្ជាក់ឲ្យតុលាការជឿបានឡើយ។ ផ្ទុយទៅវិញជនជាប់ចោទបានទទួលស្គាល់សម្លេងពិតរបស់ខ្លួនក្នុងខ្សែអាត់សម្លេងដែលដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការពិនិត្យ។ នៅដំណាក់កាលចៅក្រមស៊ើបសួរថាពិតជាសម្លេងរបស់ខ្លួនពិតប្រាកដមែន ហើយបានយកលុយលោកទៅលេងភាគហ៊ុនរដ្ឋករទឹកចាញ់អស់ ស៊ីសង្វាក់ទៅនិងឯកសារភស្តុតាងសេចក្តីសម្លងចម្លើយសន្ទនាឆ្លើយឆ្លងចេញពីអង្គចងចាំទូរស័ព្ទដៃដែលបានថតកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ និងតាមចម្លើយសាក្សីឈ្មោះ [redacted] ស្មាន់ បានបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពិតជាទៅយកលុយពីព្រះសង្ឃព្រះនាម [redacted] មុន្នី ចំនួនពីរលើកដែលជា លុយរបស់ដើមបណ្តឹងឈ្មោះ [redacted] សារីជ័យសួរវង្ស ដែលផ្ញើទុកជាមួយព្រះសង្ឃ [redacted] មុន្នី។ លើកទីមួយចំនួន ៥១៥០០ដុល្លារ ទៅទិញដី មួយកន្លែងមានទីតាំងស្ថិតនៅភូមិកាយីវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងលើកទី២ចំនួន ៣០០០០ ដុល្លារ ទៅទិញដីមួយកន្លែងទៀតមានទីតាំងស្ថិតនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយសាក្សីរូបនេះបានចូលរួមធ្វើជាសាក្សីក្នុងកិច្ចសន្យាលក់ផ្តាច់ដីទាំងពីរទីតាំងទៀតផងហើយស៊ីសង្វាក់ជាមួយនិងអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] មុន្នី និងសាក្សីឈ្មោះ [redacted] សំណាង ផងដែរ។

៣-តាមចម្លើយសាក្សីឈ្មោះ [redacted] ឡៃ, ឈ្មោះ [redacted] សុខ, [redacted] ឡេង, [redacted] សុខា និងឈ្មោះ [redacted] សារុន បានអះអាងពេលសួរដេញដោលនាពេលសវនាការ គឺបានដឹងអំពីទំនាក់ទំនងញាតិរវាងព្រះសង្ឃ [redacted] មុន្នី ជាមួយនិងដើមបណ្តឹងនិងជនជាប់ចោទជាញាតិនិងគ្នា ហើយបានដឹងអំពីឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីបានផ្ញើលុយទុកជាមួយនិងព្រះសង្ឃ [redacted] មុន្នី។ ឃើញថាការអះអាងរបស់សាក្សីទាំងនេះមិនមានផលប្រយោជន៍អ្វីដល់ការបង្ហាញឲ្យឃើញការពិតនៃអង្គហេតុខាងលើនោះទេ គប្បីតុលាការមិនលើកយកមកពិចារណាទេ។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] ឡូរីន, [redacted] ធីវយីវ, [redacted] សល់ និងឈ្មោះ [redacted] រ៉េន នាពេលសវនាការបានអះអាងប្រហាក់ប្រហែលគ្នាថា ការទិញដីទាំងពីរកន្លែងនៅកំពង់ស្ពឺ គឺដាក់ឈ្មោះ [redacted] យីវឆាយ ហើយបានបដិសេធលិខិតផ្ញើប្រាក់ទុកទិញដីចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤។ ឃើញថា ការអះអាងរបស់សាក្សីទាំងនេះ

គ្មានផលប្រយោជន៍អ្វីដល់ការបង្ហាញឲ្យឃើញការពិតនៃអង្គហេតុខាងលើទេ គប្បីតុលាការមិនលើកយកមកពិចារណានោះទេ។

៥-ទោះបីជាជនជាប់ចោទឈ្មោះ [redacted] យីវឆាយ បានឆ្លើយបដិសេធថា ពុំបានយកលុយពីព្រះសង្ឃព្រះនាម[redacted] មុន្នី ក៏ដោយ តែតុលាការបានរកឃើញភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ និងមានចម្លើយសាក្សីព្រះសង្ឃ [redacted] មុន្នី និងសាក្សី [redacted] ស្មាន់ បានឃើញជនជាប់ចោទឈ្មោះ [redacted] យីវឆាយ បានទទួលលុយពីព្រះសង្ឃសាន មុន្នី ចំនួនពីរលើក ហើយសាក្សីឈ្មោះ[redacted]សំណាង ក៏បានដឹងឮដែរ។ ចំពោះចម្លើយសាក្សីទាំងនេះស៊ីសង្វាក់ទៅនិងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចឲ្យតុលាការជឿបាន និងមានលក្ខណៈគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ បានតែបំបាត់ និងបន្លំយកទ្រព្យសម្បត្តិអ្នកដទៃដោយចេតនាជាហេតុធ្វើឲ្យខូចខាតប្រយោជន៍ដល់ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណី។ អំពើនេះស្ដែងឡើងយ៉ាងច្បាស់នូវធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។

៦-ចំពោះឯកសារភស្តុតាងដែលជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ដាក់ជូនតុលាការពិនិត្យនាពេលសវនាការមិនអាចយកមកដោះបន្ទុកបានឡើយ។ ព្រោះឯកសារទាំងនេះមិនមែនជាភស្តុតាងដោះបន្ទុកក្នុងអង្គហេតុនៃការចោទប្រកាន់ទេ ហើយក៏មិនមានមូលដ្ឋានគ្រប់គ្រាន់អាចឲ្យតុលាការជឿបានទេ។

៧-តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងក្នុងរឿងនេះដែលគឺមានមូលដ្ឋានច្បាស់លាស់និងភស្តុតាងត្រឹមត្រូវក្នុងការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពីបទ រំលោភលើទំនុកចិត្តដែលមាននៅក្នុងប្បញ្ញត្តិមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់។ នីត្យានុកូលឬធាតុច្បាប់ដែលមានចែងក្នុងមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនិង បទរំលោភលើទំនុកចិត្តពាក់ព័ន្ធនិងជាតុសត្យានុម័តនោះគឺអំពើឃើញថារឿងអង្គហេតុនេះលោក [redacted] យីវឆាយ គាត់មិនទទួល ស្គាល់ថាគាត់មិនបានយកលុយនោះទេ គាត់សុខចិត្តទទួលខុសត្រូវចំពោះមុខច្បាប់ ហើយគាត់ បាននិយាយថាមិនស្គាល់ព្រះតេជគុណ[redacted] មុន្នី។ តាមពិតទៅលោក [redacted] មុន្នី ជាសង្ឃរាជវត្ត ដោយ លោក[redacted] យីវឆាយបានមកបួសរៀនសិក្សានៅវត្ត។ លោកតា [redacted] មុន្នី ទុកចិត្តលើលោក [redacted] យីវឆាយ ពេលណាដែលលោកមិននៅគឺលោកតែងតែប្រគល់កិច្ចកបិនទាន និងត្រៃជាដើមជំនួសលោក ដោយសារតែការជឿទុកចិត្ត និងការប្រគល់កិច្ចការមួយចំនួនដោយពុំបានធ្វើលិខិតស្នាម ដោយជាក្រុមគ្រួសាររបស់គាត់។ បើពាក់ព័ន្ធលិខិតស្នាមហេតុអីបានជាគាត់មិនចោទប្រកាន់អ្នកដទៃ បែរចោទតែឈ្មោះ [redacted] យីវឆាយ ដោយសារតែគាត់ជាក្មួយបង្កើតឈ្មោះ[redacted] សារី ជាឪពុករបស់ឈ្មោះ [redacted] សារីជ័យសូរវង្ស ដែលរស់ នៅកម្ពុជាក្រោម ដោយលោក [redacted] សារីឃើញថាដីឡើងថ្លៃ និងបង្កបង្កើនផលល្អ ណាមួយដីស្រុកខ្មែរឡើងថ្លៃ ហើយគាត់ចង់បានដី។ ឈ្មោះ[redacted] សារីជ័យសូរវង្ស ទើបតែមានអាយុលើស ១៨ឆ្នាំមករៀននៅភ្នំពេញបាត់ៗ អត់ដឹងអីទេ ហើយលោកហុក យីវឆាយទើបតែសឹក និងការប្រពន្ធ។ គាត់បានប្រគល់កិច្ចការរឿងទិញដីឲ្យលោក[redacted] យីវឆាយ ព្រោះលុយគេបានផ្ញើមកឲ្យចំនួន ៩៥០០០ដុល្លារ (ប្រាំបួនម៉ឺនប្រាំពាន់ដុល្លារ)។ លោក [redacted] យីវឆាយ រកបានដីមួយកន្លែងនៅភូមិកាយីវ និងទូលព្រះតេជគុណថា គេមានដីដោយគេលក់តម្លៃប៉ុននេះៗ ទិញចែកគ្នា និងបានយកលុយពីលោកទៅទិញដីនោះ។ លើកទី២ នៅភូមិបាក់ក តម្លៃដីនោះដូចនៅក្នុងកិច្ច សន្យាទិញលក់ សួរថាហេតុអីពេលនោះមិនដាក់ឈ្មោះ [redacted] សារីជ័យសូរវង្ស តែម្ដងទៅ។ មូលហេតុដែលដឹង នោះគឺដោយសារការលក់ដីគឺមានការផ្ទេរសិទ្ធិហើយណាមួយសុទ្ធតែកូនចៅឯងមិនទៅណានោះទេ ដល់ពេល ថ្ងៃកម្មវិធីបុណ្យមិនឃើញ [redacted] យីវឆាយ មកហើយលោក [redacted] សារី សង្ស័យ និងបានសួរដេញដោលរឿងដី ហើយ [redacted] សារីជ័យសូរវង្ស បាននិយាយឲ្យផ្ទេរឈ្មោះតែហុក យីឆាយ ថាទេ បើមកតែម្នាក់ឯង។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ ហុក សារីជ័យសូរវង្សបានហៅអាជ្ញាធរមូលដ្ឋាន និងតំណាងស្រុក ដោយលោក [redacted] យីវឆាយ និយាយថាដីនេះជាដីរបស់គាត់ដីដែលរកទិញឲ្យឯងនោះមិនបានទិញទេ គឺគាត់បានយកលុយនោះ ទៅលេងភាគហ៊ុនអស់ហើយ តែគាត់បាននិយាយថាបានយកលុយនិងមែនដែលមានចំនួនទឹកប្រាក់ ១១៥០០ដុល្លារ ដោយមិនបានទិញដី តែនៅចំពោះ



Scanned with CamScanner

មុខតំណាងអយ្យការគាត់ឆ្លើយថា គាត់មិនមែនជាដីគាត់ទេ បើតុលាការរកឃើញគាត់សុខចិត្តទទួលទោស នៅចំពោះមុខចៅក្រមស៊ើបសួរគាត់ឆ្លើយថា ចម្លើយទាំងអស់ជា ចម្លើយរបស់គាត់មែន តែសំដីគាត់នៅពេលនោះ គឺគាត់ឌឺដាក់តែប៉ុណ្ណោះ។ ចម្លើយទាំងពីរដំណាក់កាលនេះគឺ មានការប្រែប្រួល ដែលធ្វើឲ្យយើងឃើញថា គឺមានចេតនាទុច្ចរិត។ សេចក្ដីស្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុនិងអង្គច្បាប់។ គប្បីតុលាការទទួលយកមកពិចារណាសម្រេចតាមច្បាប់។

៨-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានពិនិត្យសំណុំរឿងលេខ ៣៣៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ បានប្ដឹងសុំឲ្យតុលាការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពីបទៈ រំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៤។ សេចក្ដីសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់។ គប្បីតុលាការទទួលយកមកពិចារណានិងសម្រេចតាមច្បាប់។

៩-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនសុំបដិសេធបណ្ដឹងចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ និងពាក្យបណ្ដឹងបន្ថែមចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted]សារីជ័យសួរវង្ស ចោលជាអសារបង់ និងឲ្យកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] យីវឆាយ រួចខ្លួនពីបទៈ រំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៤ និងបញ្ឈប់អនុភាពដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១៥៩/១៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍។ សេចក្ដីសន្និដ្ឋាននេះពុំមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ឡើយ។ គប្បីតុលាការមិនលើកយកមកពិចារណាទេ ហើយតុលាការពិនិត្យសម្រេចតាមច្បាប់។

១០-ភស្តុតាងបានមកពីការស៊ើបសួរ ភស្តុតាងបានមកពីលទ្ធផល នៃការសួរដេញដោលនាពេលសវនាការមានភាពស៊ីសង្វាក់គ្នា ហើយមានលក្ខណៈគ្រប់គ្រាន់ជាភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ ហុក យីវ ឆាយ ដោយគ្មានវិមតិសង្ស័យឡើយ។

១១-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted] យីវឆាយ បានឆ្លើយតបទៅនិងនិយមន័យនៃអំពើរំលោភលើទំនុកចិត្តតាមបញ្ញត្តិមាត្រា៣៩១ នៃក្រមព្រហ្មទណ្ឌ ហើយទោសដែលត្រូវអនុវត្តតាមបញ្ញត្តិមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

១២-ក្រោយពីបានពិចារណាទៅលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ និងកាលៈទេសៈ នៃការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទឈ្មោះ [redacted]យីវឆាយ ឃើញថា គ្មានចំណុចណាមួយដែលអាចឲ្យតុលាការយកមកពិចារណាប្រកាសទោសការព្យួរទោសធម្មតាតាមបញ្ញត្តិមាត្រា១០៦, ១០៧នៃក្រមព្រហ្មទណ្ឌបានទេ។

១៣-ដោយហេតុថាជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ត្រូវបានសាលាឧទ្ធរណ៍បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនរួចហើយ ហើយតុលាការបានប្រកាសផ្ដន្ទាទោសដាក់ពន្ធនាគារលើសពី០១ឆ្នាំ ដោយគ្មានការព្យួរទោសទេ គប្បីតុលាការសម្រេចឲ្យចាប់ខ្លួន និងឃុំខ្លួន ជនជាប់ចោទរូបនេះតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៤-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ភេទប្រុស បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយ សណ្ដាប់ធ្នាប់សាធារណៈ និងសង្គមជាតិ ជាពិសេសធ្វើឲ្យប៉ះពាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី គប្បីតុលាការសម្រេចផ្ដន្ទាទោសលើជនជាប់ចោទរូបនេះតាមច្បាប់។

១៥-ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] យីវឆាយ មានអាយុ ៣៤ឆ្នាំ ជានីតិជន មិនមានសញ្ញាណណាមួយដែលនាំឲ្យមានការសង្ស័យ អំពីបញ្ហាស្មារតីរបស់ជនជាប់ចោទនេះឡើយ នេះបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទរូបនេះជាមនុស្សអាចយល់ ដឹងនូវអំពើ និងព្យសនកម្ម ដែលកើតចេញពីអំពើដែលរូបគេបានប្រព្រឹត្តនោះ គប្បីតុលាការពិចារណានិងផ្ដន្ទាទោសតាមច្បាប់។

១៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] យីវឆាយ ពីបទៈ **រំលោភលើទំនុកចិត្ត** តាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៤ គប្បីតុលាការពិចារណា និងផ្តន្ទាទោសជនជាប់ចោទរូបនេះតាមច្បាប់។

១៧-នាពេលសវនាការឈ្មោះ [redacted] សារីជ័យសូរវង្ស បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមានមេធាវីការពារសិទ្ធិឈ្មោះ [redacted] ម៉ៅ ធ្វើឡើងតាមកំណត់ច្បាប់។

១៨-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីជ័យសូរវង្ស បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ១០០, ០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក គប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោសឈ្មោះ** [redacted] **យីវឆាយ** ភេទប្រុស អាយុ ៣៤ឆ្នាំ មុខរបរ លក់ដូរ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **១៨ខែ** (**ដប់ប្រាំបីខែ**) គិតពីថ្ងៃចាប់ខ្លួនមកទទួលទោស ពីបទៈ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិជង្រុក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

**២-ឲ្យ**ជនជាប់ចោទឈ្មោះ [redacted] **យីវឆាយ** សងសំណងជម្ងឺចិត្តចំនួន ៤០០ ០០០ ០០០រៀល(បួនរយលានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីជ័យសូរវង្ស ការទាមទារលើសពីនេះបដិសេធចោល។

**៣-បង្គាប់ឲ្យ**ចាប់ខ្លួន និងឃុំខ្លួនពិរុទ្ធជនឈ្មោះ [redacted] **យីវឆាយ** ភេទប្រុស អាយុ ៣៤ឆ្នាំ តាមប្បញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៤-សាលក្រម**នេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ និងសម្រេចសេចក្តី ៖

-ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **យីវឆាយ** និងដើមបណ្តឹងឈ្មោះ [redacted] សារីជ័យសូរវង្ស។

-ពិរុទ្ធជនឈ្មោះ [redacted] **យីវឆាយ** និងដើមបណ្តឹងឈ្មោះ [redacted] សារីជ័យសូរវង្ស មានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះបានតាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

Scanned with CamScanner